**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ១៦៣. សសរ

# សេចក្ដីសម្រេច

## ស្ដីពី

## ការបង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ពហុកីឡាដ្ឋានជាតិមរតកតេជោ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន

**រាជរដ្ឋាភិបាលកម្ពុជា**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី ២៤ ខែ កញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៧៤.អនក្រ.បក ចុះថ្ងៃទី ២២ ខែឧសភា ឆ្នាំ២០១២ ស្ដីពីការដាក់ឲ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- យោងតាមតម្រូវការចាំបាច់របស់រាជរដ្ឋាភិបាល

**សម្រេច**

**ប្រការ ១ :** បង្កើតគណៈកម្មការបច្ចេកទេសសម្រាប់គម្រោងសាងសង់ពហុកីឡាដ្ឋានជាតិមរតកតេជោ ក្នុងក្របខ័ណ្ឌហិរញ្ញប្បទានឥតសំណងពីសាធារណរដ្ឋប្រជាមានិតចិន ។

**ប្រការ ២ :** គណៈកម្មការបច្ចេកទេសនេះមានសមាសភាព ដូចខាងក្រោម÷

| | | |
|---|---|---|
| ១ - | ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា | ប្រធាន |
| ២ - | តំណាងក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ៣ - | តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| ៤ - | តំណាងក្រសួងមហាផ្ទៃ | សមាជិក |

www.pheakdeylaw.com

៥- តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក

៦- តំណាងក្រសួងបរិស្ថាន សមាជិក

៧- តំណាងសាលារាជធានីភ្នំពេញ សមាជិក

**ប្រការ ៣ :** គណៈកម្មការបច្ចេកទេសនេះមានភារកិច្ច ដូចខាងក្រោម÷

-ដឹកនាំ និងសម្របសម្រួលជាមួយភាគីចិនពាក់ព័ន្ធលើការងារសិក្សាសមិទ្ធិលទ្ធភាព ការរៀបចំគម្រោង និងការអនុវត្តគម្រោង។

-ពិនិត្យ សម្រេចលើលក្ខណៈបច្ចេកទេស តម្លៃ និងការអនុវត្តនីតិវិធីនានារបស់គម្រោង រួមទាំងការចុះហត្ថលេខាលើកិច្ចសន្យាពាក់ព័ន្ធនានារបស់គម្រោង។

-ត្រូវរាយការណ៍ជាប្រចាំអំពីលទ្ធផលនៃការងារអនុវត្តគម្រោងជូនអង្គភាព ក្រសួង-ស្ថាប័នតាមភាពចាំបាច់។ ក្នុងករណីត្រូវចាត់វិធានការលើសពីសមត្ថកិច្ចរបស់ខ្លួន គណៈកម្មការអាចសហការ ឬស្នើអោយមានកិច្ចសហការពី ក្រសួង-ស្ថាប័នពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ តាមតម្រូវការចាំបាច់ជាក់ស្តែង។

**ប្រការ ៤ :** គណៈកម្មការបច្ចេកទេសមានសិទ្ធិប្រើប្រាស់ត្រារបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា។

**ប្រការ ៥ :** ប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រសួង-ស្ថាប័នពាក់ព័ន្ធ និងសមាសភាពដូចមានចែងក្នុងប្រការ ២ ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ធ្នូ ឆ្នាំ ២០១៤

នាយករដ្ឋមន្ត្រី

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**ចម្លងជូន:**

-ក្រសួងព្រះបរមរាជវាំង

-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា

-អគ្គលេខាធិការដ្ឋានរដ្ឋសភា

-អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល

-ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

-ខុទ្ទកាល័យឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត គាត ឈន់ ឧបនាយករដ្ឋមន្ត្រីប្រចាំការ

-ដូចប្រការ ២

-ឯកសារ-កាលប្បវត្តិ

www.pheakdeylaw.com